ជូនចំពោះ ក្រុមគ្រួសារជាទីគោរព៖

ការអានគឺជាមូលដ្ឋាននៃការសិក្សាក្នុងជីវិត ហើយអក្ខរកម្មអាចនាំមកនូវអ្វីៗដែលជួយសិស្សរបស់យើងឱ្យរីកចម្រើន។

ដើម្បីលើកកម្ពស់អក្ខរកម្ម និងជួយសិស្សឱ្យពង្រីកជំនាញអក្ខរកម្ម ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា មានសេចក្តីសោមនស្សរីករាយក្នុងការប្រកាស "ការផ្តើមគំនិតក្នុងការអានសៀវភៅ ២០ ក្បាល ក្នុងរយៈពេល ២០ សប្តាហ៍ (20 in 20 Reading Initiative)" ។ តាមរយៈនៃការផ្តើមគំនិតថ្មីនេះ យើងជំរុញសិស្សថ្នាក់ទី ៣ ឱ្យអានសៀវភៅ ២០ ក្បាល ក្នុងរយៈពេល ២០ សប្តាហ៍ ឱ្យចប់ត្រឹមថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២៣។

សិស្សម្នាក់ៗនឹងទទួលសៀវភៅដែលមានចំណាប់អារម្មណ៍ខ្ពស់ ហើយទាក់ទងនឹងវប្បធម៌ ចំនួន ១០ ក្បាល ដើម្បីបង្កើតបណ្ណាល័យផ្ទាល់ខ្លួនរបស់សិស្ស បង្កើនភាពសប្បាយរីករាយរបស់សិស្សក្នុងការអាន បណ្តុះបណ្តាលជំនាញអក្ខរកម្មរបស់ពួកគេ និងពង្រីកការឆ្លុះបញ្ចាំងរបស់ពួកគេលើខ្លួនឯង និងពិភពលោកជុំវិញពួកគេ។ សិស្សត្រូវបានជំរុញឱ្យតាមដានការរីកចម្រើនរបស់ពួកគេ ត្រឹមថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២៣។ សិស្សដែលអានចប់ដោយជោគជ័យតាមការផ្តើមគំនិតនៃការអានចប់សៀវភៅ ២០ ក្បាល ក្នុងរយៈពេល ២០ សប្តាហ៍ នឹងទទួលវត្ថុលើកទឹកចិត្ត ចំពោះការខិតខំប្រឹងប្រែងរបស់ពួកគេ។

យើងខ្ញុំសូមជំរុញលោកអ្នកឱ្យចូលរួមក្នុងការផ្តើមគំនិតនេះ និងជួយអភិវឌ្ឍសមត្ថភាពអាន ការយល់ដឹង និងជំនាញអក្ខរកម្ម របស់កូនលោកអ្នក។

នេះគឺជាគន្លឹះ និងដំបូន្មានមួយចំនួនសម្រាប់លោកអ្នកដើម្បីបង្កើនបទពិសោធន៍ទាំងនេះនៅផ្ទះ៖
**អានជាមួយកូន៖**

- ពេលអានជាមួយកូន លោកអ្នក និងកូនរបស់លោកអ្នកប្តូរវេនគ្នាអានជំពូកក្នុងសៀវភៅ។ នៅពេលអានសុំឲ្យកូនរបស់លោកអ្នកភ្ជាប់សាច់រឿង ដោយសួរសំណួរដូចជា៖
    - ហេតុអ្វីបានជាកូនជ្រើសរើសសៀវភៅនេះ?
    - តើចំណងជើងជួយកូនស្វែងរកព័ត៌មានដោយរបៀបណា?
    - តើកូនដឹងថាអ្វីដែលកូននិយាយអំពីសៀវភៅនេះត្រឹមត្រូវដោយរបៀបណា?

    ○ តើអ្នកនិពន្ធបង្ហាញព័ត៌មានដោយរបៀបណា?

**មុនពេល - ក្នុងអំឡុងពេល - ក្រោយពេល អាន**

- សួរសំណួរ មុនពេល ក្នុងអំឡុងពេល និងក្រោយពេល អានឮៗ។ នេះអាចជួយកូនរបស់លោកអ្នកផ្តោតការយកចិត្តទុកដាក់លើគំនិតផ្សេងៗក្នុងរឿង។ មុនពេលអាន សូមមើលក្របសៀវភៅ ហើយនិយាយអំពីអ្វីៗដែលអាចកើតឡើងក្នុងរឿង។ ក្នុងអំឡុងពេលអាន សួរកូនថាតើមានសំណួរអ្វីខ្លះអំពីរឿងនេះ។ ក្រោយពេលអានចប់ និយាយអំពីអ្វីដែលបានកើតឡើង។ សុំឱ្យកូនរបស់លោកអ្នកសង្ខេបរឿង ហើយរៀបរាប់ពីរឿងរ៉ាវដែលគេដឹង ឬធ្លាប់ជួបប្រទះ រួចមកហើយ។

**សិស្សដែលត្រូវការរៀនភាសាអង់គ្លេស៖**

- ប្រសិនបើលោកអ្នកប្រើភាសាផ្សេងនៅផ្ទះ និយាយ និងអានទៅកូនរបស់លោកអ្នកជាភាសានោះ។ នេះអាចជួយបង្កើនវាក្យសព្ទ និងបង្កើតទំនាក់ទំនងនៅសាលា។ វាក៏អាចបង្កើនការចង់ដឹងចង់ឃើញ និងការត្រៀមខ្លួនរៀននៅសាលាផងដែរ។ ឱកាសសិក្សាជាភាសាដែលនិយាយនៅផ្ទះនឹងជួយឱ្យរៀនអក្សរសាស្ត្រជាភាសាអង់គ្លេស។

បន្ថែមពីលើគន្លឹះទាំងនេះ នេះគឺជាឱកាស និងកម្មវិធីអានបន្ថែម៖

- **ការអានតាមអនឡាញ (Digital Reading Community)៖** ក្រុមគ្រួសារទទួលបានសារប្រាប់ឱ្យមានការពិភាក្សាអំពីសៀវភៅ ល្បែងដែលទាក់ទងនឹងសៀវភៅ ការជួបអ្នកនិពន្ធតាមអ៊ិនធ័រណិត បណ្ណាល័យអនឡាញដែលមានសៀវភៅជាច្រើនទៀតសម្រាប់អាន និងសកម្មភាពផ្សេងទៀតនៅ គេហទំព័រ http://scholastic.com/phillyreadandgrow
- **សំណួរផ្សេងៗ៖** អ៊ីមែលទៅ AskTerica@scholastic.org
- **បណ្ណាល័យអនឡាញ (Power Library)៖** គឺជាទំព័រវិបសែអនឡាញសម្រាប់បណ្ណាល័យទាំងអស់ដែលរដ្ឋផិនស៊ីលវេនញ៉ាផ្តល់ឱ្យ។ នេះគឺជាកន្លែងដើម្បីស្វែងរកការចូលមើល កាសែត ទស្សនាវដ្តី សារព័ត៌មាន ឯកសារប្រវត្តិសាស្ត្រ និងរូបថត បន្ទុកទិន្នន័យអនឡាញ និងសៀវភៅអេឡិចត្រូនិច បាន ២៤ ម៉ោង ក្នុងមួយថ្ងៃ ៧ ថ្ងៃ ក្នុងមួយសប្តាហ៍។ ស្រាវជ្រាវប្រធានបទ។ ស្វែងយល់អំពីប្រវត្តិគ្រួសាររបស់លោកអ្នក។ ស្វែងរកចំណងជើង។ ស្វែងរកជម្រើសអាជីព។ មានទាំងអស់នៅទីនេះ នៅ POWER Library។ បណ្តាញតភ្ជាប់៖ https://sites.google.com/philasd.org/sdppowerlibrary/home

ដើម្បីគាំទ្រការផ្តើមគំនិតនេះ យើងនឹងចែករំលែកការអានឮៗតាមរយៈគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់យើង។ យើងខ្ញុំក៏សុំឱ្យលោកអ្នកចែករំលែករូបថតរបស់លោកអ្នកជាមួយយើងផងដែរ! សូមផ្ញើរូបថតកូន

របស់លោកអ្នកមកជាមួយសៀវភៅ និង/ឬ ការអានមកយើងតាមអ៊ីមែល academyprojects@philasd.org។ រូបថតទាំងនេះអាចត្រូវបានប្រើប្រាស់នៅលើវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ក្រសួងអប់រំ។

សូមអរគុណចំពោះការគាំទ្ររបស់លោកអ្នក និងសម្រាប់ការចូលរួមក្នុងបទពិសោធន៍នៃការអានរបស់កូនលោកអ្នកនៅផ្ទះ។ ការគាំទ្រការផ្តើមគំនិតនេះអាចអភិវឌ្ឍសមត្ថភាពអានរបស់កូនលោកអ្នក ជំនាញភាសា និងជំរុញឱ្យមានការស្រឡាញ់ការអាន។

ប្រសិនបើលោកអ្នកមានសំណួរអ្វី សូមទាក់ទងតាមអ៊ីមែលមក academicprojects@philasd.org។

ដោយសេចក្តីស្មោះស្ម័គ្រ
ការិយាល័យផ្តល់ជំនួយផ្នែកសិក្សាធិការ